**ការសិក្សាពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចដោយកូវីដ១៩.**
**សេចក្តីសង្ខេបលទ្ធផលរបស់ចំណងជើង**
**ការប្រមូលទិន្នន័យលើកទី១: ខែ ឧសភា ឆ្នាំ ២០២០**
អង្គការវេទិការអនាគត និង ក្រុមហ៊ុនអង្គរស្រាវជ្រាវកម្ពុជា

## ការជម្រុញនៅលើគម្រោង

ជម្ងឺវីរុសកូរ៉ូណា២០១៩ (កូវីដ-១៩) គឺជាជម្ងឺឆ្លងមួយដែលបណ្តាលមកពី វីរុសកូរ៉ូណា ២ (សា-កូ-២) ដែលមានរោគសញ្ញារលាកផ្លូវដង្ហើមស្រួចស្រាវ។ គេរកឃើញជម្ងឺនេះនៅក្នុងឆ្នាំ២០១៩ ស្ថិតក្នុងក្រុងវូហាន ជាទីក្រុងរបស់ខេត្តហ៊ូប៊ី ប្រទេសចិន ហើយបានរីករាលដាលពាសពេញពិភពលោក ចាប់តាំងពីពេលនោះមក ដែលជាលទ្ធផលនាំឲ្យមានការរាតត្បាតជាសកលនៃវីរុសកូរ៉ូណានេះ នៅចន្លោះឆ្នាំ២០១៩ និង ឆ្នាំ២០២០។ បន្ទាប់ពីមានការឆ្លងរាលដាលឥតឈប់ឈរនៃមេរោគនេះ រដ្ឋាភិបាលជាច្រើននៅលើពិភពលោក បានធ្វើសេចក្តីសម្រេចបិទព្រំប្រទល់របស់ខ្លួន ហើយបញ្ជាអោយកន្លែងលក់ដូរដែលមិនសំខាន់ជាច្រើន បិទទ្វារជាបណ្តោះអាសន្ន ហើយបញ្ជាអោយប្រជាពលរដ្ឋស្នាក់នៅតែក្នុងគេហដ្ឋាន[1]។ ការវិភាគថ្មីៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (អេឌីប៊ី) បានប៉ាន់ប្រមាណថា ការផ្ទុះឡើងនៃមេរោគកូរ៉ូណានេះ អាចនឹងធ្វើអោយខាតបង់ដល់សេដ្ឋកិច្ចពិភពលោកប្រមាណ ៤,១ លានលាន ទៅ ៥,៤ លានលានដុល្លារ (ការខាតបង់ ៤,៥ - ៥,៩ ភាគរយនៃផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក (ជីឌីភី) ស្ថិតក្នុងស្ថានភាពប្រសើរឡើងនៃ «ការឆ្លើយតបសមស្របរបស់គោលនយោបាយរដ្ឋាភិបាល»[2]។ នៅក្នុងស្ថានការណ៍នៃការធ្វើអន្តរាគមន៍ដែលគ្មានប្រសិទ្ធិភាពឬគ្មានប្រសិទ្ធផល ផលប៉ះពាល់នេះត្រូវបានគេប៉ាន់ប្រមាណថា នឹងធ្វើអោយមានការខាតបង់សរុបរបស់ពិភពលោក ៨,៨ លាន លាន ដុល្លារ (៩,៧ ភាគរយនៃផលិតផលសរុបពិភពលោក)។

---

[1] See https://www.imf.org/en/Topics/imf-and-covid19/Policy-Responses-to-COVID-19 for a breakdown of national policy responses to the crisis.
[2] Asian Development Bank website. Available at https://www.adb.org/news/videos/covid-19-s-global-economic-impactcould-reach-8-8-trillion-adb.

ទោះបីជាកម្រិតនៃការឆ្លងជាផ្លូវការនៅក្នុងប្រទេសកម្ពុជាមានកម្រិតមធ្យមក៏ដោយ[3] ក៏រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា បានរាប់រងធ្វើនូវវិធានការនយោបាយមួយចំនួន ដើម្បីគ្រប់គ្រងទៅលើការផ្ទុះឡើងនៃជម្ងឺនេះផងដែរ រួមមាន៖

- ការបង្កើតក្រុមការងារដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បី៖ (១) គ្រប់គ្រងតម្លៃនិងការផ្គត់ផ្គង់ទំនិញយុទ្ធសាស្ត្រ (សេចក្តីសម្រេច លេខ. ០២៤) (២) សិក្សា និងធ្វើផែនការ វិធានការធនាគានិងរូបិយវត្ថុ ដើម្បីគាំទ្រដល់គណៈកម្មាធិការស្តីគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (សេចក្តីសម្រេច លេខ. ០២៨) និង (៣) ធ្វើផែនការ សម្រាប់នយោបាយថវិការជំនួយសង្គមនិងហរិញ្ញវត្ថុ (សេចក្តីសម្រេច លេខ. ០២7)
- ការសិក្សាផ្តោតទៅលើវិធានការការពារជម្ងឺកូវីដ-១៩ មានដូចជា៖ (៤) សម្ភារៈការពារខ្លួនរបស់ក្រសួងសុខាភិបាល និងការណែនាំសម្អាតម្ចាស់យានយន្តដឹកជញ្ជូន និងអ្នកធ្វើដំណើរលើយានយន្តដឹកជញ្ជូនរួមគ្នា (៥) ការផ្អាករាល់អាជីវកម្មសុខភាព ស្បា និង ម៉ាស្សា ដោយក្រសួងទេសចរណ៍ និង (៦) សេចក្តីសម្រេចរបស់ក្រសួងអប់រំយុវជន និងកីឡា អោយផ្អាកការចូលរៀន ព្រមទាំងសកម្មភាពកីឡាផ្សេងៗ ដែលនាំអោយមានការជួបជុំនៅក្នុងទីសាធារណៈ។
- ការអនុម័តច្បាប់ដាក់ប្រទេសក្នុងគ្រាមានអាសន្ន ផ្អែកតាមមាត្រា២២នៃច្បាប់រដ្ឋធម្មនុញ្ញ
- វិធានការការពារនៅតាមព្រំដែន ដោយរឹតបន្តឹងចលនាជនបរទេសដែលធ្វើដំណើរមកដល់ព្រះរាជាណាចក្រ រហូតទាល់តែមានការបញ្ជាក់ការវិន្និច្ឆ័យរោគថាគ្មាន កូវីដ-១៩។ វិធានការជាច្រើននាពេលបច្ចុប្បន្ន ទៀមទាការទទួលយកទិដ្ឋាការជាមុនមុនពេលធ្វើដំណើរមក មានសំបុត្រសុខភាព ដែលបញ្ជាក់ដោយអាជ្ញាធរសុខភាព ថាគ្មានជម្ងឺកូវីដ-១៩ ផ្តល់ការធានាសម្រាប់រ៉ាបរងផ្នែកសុខភាពអប្បបរិមា ៥០.០០០ដុល្លារអាមេរិក និងប្រាក់តម្កល់ ៣.០០០ដុល្លារអាមេរិក សម្រាប់ថ្លៃសេវាកូវីដ-១៩ នៅប្រលានយន្តហោះដែលធ្វើដំណើរមកដល់ ចំណាយលើការព្យាបាលសុខភាព (រួមមាន ការធ្វើតេស្តរកមេរោគកូវីដ-១៩ ដែលតម្រូវដោយច្បាប់) និងការស្នាក់អាស្រ័យ។

ខណៈដែលការឆ្លងរាលដាលជាសាកលចេះបន្តទៅមុខ ទាំងនៅក្នុងប្រទេសនិងក្រៅប្រទេស គេរំពឹងថារាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា នឹងបន្តចាត់វិធានការថែមទៀត ដើម្បីការពារការឆ្លងរោគបន្ថែម។ ដោយឡែក ឥទ្ធិពលនៃការរាតត្បាតជាសកលនេះ នៅតែបន្តប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជា ដែលបានធ្វើអោយអាក់ខានដល់ការធ្វើដំណើរនិងទេសចរណ៍ សង្វាក់ផ្គត់ផ្គង់ និងការផ្គត់ផ្គង់កម្លាំងពលកម្ម។ ខណៈដែលសហគ្រាសធំៗនឹងជួបនូវផលពិបាកផ្នែកហរិញ្ញវត្ថុ វិស័យព័ត៌មាន កសិករ សហគ្រាសតូចៗ អាចនឹងជួបនូវបញ្ហាប្រឈមធ្ងន់ធ្ងរច្រើនទៀត ដែលកើតចេញពីការអនុវត្តនៃវិធានការការពារនៅក្នុងប្រទេសកម្ពុជា។ ស្ថានភាពនាពេលបច្ចុប្បន្ននេះ ក៏នឹងមានផលប៉ះពាល់ផងដែរដល់កម្មកររកប្រាក់កម្រៃ មានចំនួនជាងពាក់កណ្តាល (៥១%) នៃប្រជាជនសកម្ម ដោយផ្អែកតាមការសិក្សាសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ២០១៧(ស៊ីអេសអ៊ីអេស)។ ជាងនេះទៅទៀត

[3] Cambodia has reported 141 cases at the time of writing (Source: https://kh.usembassy.gov/covid-19-information/).

សេវាអាហារនិងបដិសណ្ឋារកិច្ច បុគ្គលិកកម្សាន្ត ត្រូវបានផ្អាក ឬ កាត់បន្ថយសកម្មភាពរបស់ខ្លួនជាច្រើន ដោយសារការបិទព្រំដែន ការធ្វើមាតុភូមិនិវត្តនៃជនទេសចរណ៍និងជនចំណាកស្រុករាប់រយនាក់ រួមទាំងការដាក់កម្រិតនៃការជួបជុំ និងការប៉ះពាល់គ្នា។ បន្ថែមលើនេះទៀត រោងចក្រជាច្រើននៅក្នុងប្រទេសកម្ពុជាបានចាប់ផ្ដើមបិទទ្វារ ដែលនាំអោយកម្មកររាប់ពាន់នាក់បានបាត់បង់ការងារ។ អ្នកនាំពាក្យរបស់ក្រសួងការងារប៉ាន់ប្រមាណថា «រោងចក្រយ៉ាងហោចណាស់ ២០០ នឹងប្រឈមនូវការខ្វះខាតវត្ថុធាតុដើម ហើយ ស្ថានការណ៍ដ៏ធ្ងន់ធ្ងរបំផុតនោះ គឺកម្មកររោងចក្រចំនួន១៦០.០០០នាក់នឹងទទួលរងផលប៉ះពាល់ ដោយសារតែការផ្ទុះឡើងនៃជម្ងឺកូវីដ-១៩នេះ»[4]។ ទោះបីជាឧស្សាហ៍កម្មកាត់ដេរ សំណង់ ទេសចរណ៍ គឺជាក្បាលម៉ាស៊ីននៃកំនើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏វិស័យកសិកម្មត្រូវបានអះអាងថាមានប្រមាណជា ៣៥% នៃផលិតផលសរុបក្នុងស្រុក[5] និងបានផ្ដល់ការងារដល់ប្រជាជនក្នុងបរិមាណដ៏ច្រើន។

**វិធីសាស្ត្រនិងវត្ថុបំណងរបស់គម្រោង**

ជាមួយគ្នានេះ ហើយដោយសារដឹងថាមានគម្លាតយ៉ាងឆ្ងាយនៅក្នុងទិន្នន័យថ្នាក់មូលដ្ឋាន វេទិការអនាគតនិងអង្គរស្រាវជ្រាវកម្ពុជា កំពុងរួមគ្នាធ្វើការសិក្សាទៅលើផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចដោយជម្ងឺកូវីដ-១៩។ ជាពិសេស គម្រោងនេះកំពុងតែធ្វើការសិក្សាពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃមេរោគកូវីដ-១៩ លើការបំពេញសកម្មភាពផ្សេងៗរបស់ប្រជាពលរដ្ឋកម្ពុជា ដែលគេរំពឹងថាវានឹងរងផលប៉ះពាល់ខ្លាំងជាងគេ ដោយសារការរាតត្បាតជាសកលនេះ (កសិករ កម្មកររកប្រាក់កម្រៃ គ្រួសារមានសហគ្រាសតូចៗ)។ ដោយប្រើនូវវិធីសាស្ត្រជ្រើសរើសសំណាកផ្អែកទៅក្រុម សំណាកត្រូវបានចែកជាក្រុម ជាថ្នាក់សកម្មភាព ថ្នាក់ភូមិ និង ថ្នាក់ខេត្ត ។ ការសិក្សានេះ គឺជាការសិក្សាតាមខ្សែបណ្ដោយ ដោយផ្ដោតទៅលើ កម្មកររកប្រាក់កម្រៃ គ្រួសារមានសហគ្រាសខ្នាតតូចៗ និង បណ្ដាកសិករនៅក្នុងខេត្តចំនួនបួន[6] និងនៅក្នុងទីក្រុងភ្នំពេញ។ ប្លង់សំណាកផ្ដល់ជូននៅក្នុងតារាង១។

**តារាង ១. ប្លង់សំណាក**

| **លំដាប់សំណាក** | **កម្រិត** | **ទំហំ** | **វិធីសាស្ត្រជ្រើសរើស** |
|---|---|---|---|
| **ខេត្ត** | | 5 | គោលបំណង – ភ្នំពេញ, កំពត, សៀមរាប, ស្វាយរៀង, និងកំពង់ស្ពឺ |
| **ស្រុក** | 2/ ខេត្ត | 10 | ចៃដន្យ |
| **ភូមិ (ខ្នាតសំណាកសំខាន់ៗ)** | 5/ ស្រុក[7] | 54 | ចៃដន្យ – ប្រូបាបនៃបរិមាណទៅតាមទំហំ |

[4] Lipes Joshua, 27 Feb. 2020, *Coronavirus Effect on Supply Chain Will Impact 200 Factories, 160,000 Workers in Cambodia: Official,* Radio free Asia. Last consulted on 30 March 2020. Available at: https://www.rfa.org/english/news/cambodia/impact-02272020144207.html

[5] FAO, Cambodia at a glance. Last consulted on 30 March 2020. Available at: http://www.fao.org/cambodia/fao-incambodia/cambodia-at-a-glance/en/

[6] Kampot, Kampong Speu, Svay Rieng, and Siem Reap.

[7] Four additional villages were selected in Russey Keo District to mitigate challenges in another district.

| | | | |
|---|---|---|---|
| **គ្រួសារ** | 20/ ភូមិ | 1,087 | ចៃដន្យ (ការដើរចាប់សំណាកតាមកម្មវិធីអ៊ីភីអាយ) |
| **មេភូមិ** | 1/ ភូមិ | 54 | គោលបំណង |
| **ការសម្ភាសន៍សរុប** | | **1,134** | |

**លទ្ធផលជោគជ័យ ចំណងជើង និង បុគ្គលិកលក្ខណៈអ្នកតបសម្ភាសន៍**

គោលបំណងនៃក្រដាស់នេះ គឺផ្តល់ការស្វែងរកសំខាន់ៗ ពីការប្រមូលទិន្នន័យនៅជុំទី១ តាមទម្រង់ហេតុការណ៍និងទូរលេខ ភ្ជាប់ជាមួយការវិភាគនិងការយល់ដឹងមួយចំនួន។ នៅក្នុងដំណោះស្រាយរបស់ពួកយើង មានប្រភពសំខាន់ៗពីរដែលបានផ្តល់ការយល់ដឹងគឺ គ្រួសារ និង មេភូមិ។ ពួកយើងនឹងធ្វើការចាប់ផ្តើមជាមួយលទ្ធផលពីមេភូមិ។

**មេភូមិ**

តួនាទីរបស់មេភូមិមានភាពសំខាន់ចំបង់នៅក្នុងការប្រមូលការចូលរួមចំណែកដែលតម្រូវដោយច្បាប់ពីអ្នកភូមិមូលដ្ឋាន ចំពោះគម្រោងអភិវឌ្ឍន៍ការផ្សព្វផ្សាយព័ត៌មានទៅដល់អ្នកភូមិ និងដើរតួជាយន្តការគាំទ្រផ្នែករដ្ឋបាលសម្រាប់អាជ្ញាធរឃុំ[8]។ នៅក្នុងន័យនេះ ពួកគាត់គឺជាប្រភពដ៏មានតម្លៃមួយនៃការយល់ដឹងថ្នាក់ភូមិសំដៅទៅលើព្រឹត្តិការណ៍ដែលកើតមាននៅក្នុងសង្គម សុខភាព សេដ្ឋកិច្ច និងហេតុការណ៍របស់អ្នកភូមិ។

បុគ្គលិកលក្ខណៈរបស់អ្នកតបសម្ភាសន៍ទាំងនេះមាននៅក្នុងតារាង ២។

**តារាង ២. បុគ្គលិកលក្ខណៈរបស់មេភូមិ**

| **អ្នកតបសម្ភាសន៍** | |
|---|---|
| ភូមិ | 54 |
| ប្រជាជនសរុប | 136,984 |
| លេខសំគាល់គ្រួសារសរុប | 32,538 |
| មេភូមិ | |
| ប្រុស | 87% |
| អាយុមធ្យម (ឆ្នាំ) | 59.8 |
| ចំនួនឆ្នាំជាមធ្យមធ្វើជាមេភូមិ | 15 |

នៅពេលសួរសំនួរថា « តើជម្ងឺកូវីដ-១៩ ប៉ះពាល់ដល់អ្នកភូមិនិងភូមិរបស់អ្នកដែរឬទេ?» ៩៤ ភាគរយដែលមេភូមិបានឆ្លើយគឺថាវាប៉ះពាល់។ រូបភាព ១ ជាលទ្ធផលរបស់សំនួរតាមដានដែលកំណត់ពីលក្ខណៈជាក់លាក់ ដែលអ្នកភូមិបានរងផលប៉ះពាល់។

**រូបភាព ១. ផលប៉ះនៃជម្ងឺកូវីដ-១៩ លើអ្នកភូមិ**

[8] Rusten et al. 2004, as cited in Vimealea et al. 2009.




សំនួរ: តើអ្នកគិតថាវាប៉ះពាល់ដល់អ្នកភូមិរបស់អ្នកយ៉ាងដូចម្ដេច?

បន្ថែមពីលើផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ មកលើអ្នកភូមិ មេភូមិបានផ្តល់ការយល់ដឹងលើគំរូផ្សេងៗដែលបានកើតឡើងនៅចន្លោះខែមករា ឆ្នាំ២០២០ និងខែមេសា ឆ្នាំ២០២០ រួមមានៈ ការបិទសហគ្រាសលក្ខណៈគ្រួសារ ១.០៨៣ (១០,៥ ភាគរយ)និង ការធ្លាក់ចុះពិធីបុណ្យ ភូមិ ៤២ ភាគរយ (រូបភាព ២) និង ការធ្លាក់ចុះ៣២ភាគរយនៃអំពើហឹង្សាក្នុងគ្រួសារ  (រូបភាព ៣)។

**រូបភាព ២. ពិធីបុណ្យនៅតាមភូមិ (ខែមករា និង ខែមេសា ឆ្នាំ២០២០)**




សំនួរ: តើមានពិធីបុណ្យចំនួនប៉ុន្មាន ក្នុងខែមករា ឆ្នាំ២០២០ (ខែមេសា ឆ្នាំ២០២០) នៅក្នុងភូមិរបស់អ្នក?

**រូបភាព ៣. ករណីនៃអំពើហឹង្សាក្នុងគ្រួសារ (ខែមករា និង ខែមេសា ឆ្នាំ២០២០)**




សំនួរ: តើករណីអំពើហិង្សាក្នុងគ្រួសារមានចំនួនប៉ុន្មានដែលអ្នកបានដឹង នៅក្នុងខែមករា និង ខែមេសា ឆ្នាំ២០២០?

**គ្រួសារ**

ជាវត្ថុបំណងសំខាន់នៃការសិក្សានេះ គ្រួសារជាច្រើនត្រូវបានធ្វើសម្ភាសន៍ដើម្បីកំណត់ដឹងពីការផ្លាស់ប្តូរនៃស្ថានភាពសេដ្ឋកិច្ច ដែលឡើងពីការឆ្លងរាលដាលជាសកលនៃជម្ងឺកូវីដ-១៩។ តារាង ៣ មានបុគ្គលិកលក្ខណៈរបស់អ្នកតបសម្ភាសន៍ជាលក្ខណៈគ្រួសារ។ ក្នុងចំណោមអ្នកតបសម្ភាសន៍ ១.០៨៧នាក់ មាន ៩៩៣នាក់ ដំណើរការសហគ្រាសជាលក្ខណៈគ្រួសារ។ ក្នុងចំណោមកម្មកររកប្រាក់កម្រៃ ៣១០នាក់[9] ដែលធ្វើការនៅតាមខេត្តផ្សេងៗ និង ២៧នាក់ដែលធ្វើការនៅក្រៅប្រទេសមាន ៤២,៧% បានវិលត្រឡប់មកវិញដោយសារតែកន្លែងការងារបិទទ្វារ និង ៣៤,៧% ត្រូវគេប្រាប់ថាត្រឡប់មកវិញព្រោះខ្លាចជម្ងឺកូវីដ-១៩។

**តារាង ៣. បុគ្គលិកលក្ខណៈគ្រួសារ**

| **អ្នកតបសម្ភាសន៍** | |
|---|---|
| គ្រួសារដែលបានសម្ភាសន៍ | 1,087 |
| ចំនួនមធ្យមនៃសមាជិកគ្រួសារ | 4.99 |
| ថ្នាក់សិក្សាជាមធ្យម (ចូលសាលា) | 5.5 |
| ខ្មែរ | 96.6% |

រូបភាព ៤ មានលទ្ធផលនៃចំណែកប្រាក់ចំណូលរបស់គ្រួសារដែលបានសិក្សាស្រាវជ្រាវ។ នៅចន្លោះខែមករា និងខែមេសា ឆ្នាំ២០២០ គ្រសារដែលមានជីវភាពមធ្យមមាន ៤០ ភាគរយ បានធ្លាក់ចុះប្រាក់ចំណូល។ នៅពេលត្រូវសួរអោយឆ្លើយតបទៅលើហេតុផលនៃការប្រែប្រួលនេះ (តារាង ៤) អ្នកតបសម្ភាសន៍បានលើកឡើងថា ការខ្វះអតិថិជនគឺជាបញ្ហាចំបង។ អំពីគោលជំហរប្រាក់ចំណូលផ្ទាល់ខ្លួន ការបិទកន្លែងពាណិជ្ជកម្មនិងរោងចក្រផ្សេងៗ ត្រូវបានចាត់ទុកថាជាប្រភពសំខាន់បំផុតនៃប្រាក់ចំណូលដែលបានធ្លាក់ចុះ។ ទំនោរនៃការធ្លាក់ចុះដូចគ្នានេះ អាចមើលឃើញនៅក្នុងកម្រិតសន្សំរបស់គ្រួសារ (រូបភាព

[9] Of a total 1,675

៥)។ នៅចន្លោះខែមករា និងខែមេសា មានការធ្លាក់ចុះចំនួនគ្រួសារ ដែលបានប្រាប់ថាបានសន្សំលុយ ផ្លាទីន[10] និង/ឬ មាសសុទ្ធ។ ដូចគ្នានេះដែរ ចន្លោះខែមករា និង ខែមេសា មានការរាយការណ៍ពីការធ្លាក់ចុះនៃការផ្ញើរប្រាក់អោយ ១/៣ ក្នុងបរិមាណមធ្យម ១៥០ដុល្លារទៅ១០០ដុល្លារ[11]។

**រូបភាព ៤. ប្រាក់ចំណូលគ្រួសារដែលបានរាយការណ៍ជាដុល្លារ (ខែមករា និង ខែមេសា ឆ្នាំ២០២០)**




សំនួរ: តើសហគ្រាសជាលក្ខណៈគ្រួសាររបស់អ្នកមានប្រាក់ចំណូលសរុបប៉ុន្មាន (ប្រាក់កម្រៃ) [គ្រួសារ] ក្នុងខែមករា (ខែមេសា) ឆ្នាំ២០២០?

តារាង ៤. មូលហេតុនៃផ្លាស់ប្តូរប្រាក់ចំណូលដែលបានរាយការណ៍

| **មូលហេតុសំខាន់ៗដែលកម្មកររកប្រាក់កម្រៃបានរាយការណ៍ពីផ្លាស់ប្តូរប្រាក់ចំណូល (n=882)** | |
|---|---|
| កន្លែងពាណិជ្ជកម្ម/រោងចក្របិទទ្វារជាបណ្តោះអាសន្ន | 34.0% |
| កាត់បន្ថយថ្ងៃ/ម៉ោងធ្វើការ | 25.7% |
| គ្មានលើសម៉ោង | 19.4% |
| **បញ្ហាសំខាន់ៗ ដែលម្ចាស់សហគ្រាសលក្ខណៈគ្រួសារបានជួបក្នុងដំណើរការអាជីវកម្ម (n=765)** | |
| ខ្វះអតិថិជន | 73.9% |
| ខ្វះការលក់ | 54.7% |
| អតិថិជនខ្លាចជម្ងឺកូវីដ-១៩ | 53.5% |

[10] platin in Khmer describes alloyed gold between 50-70% purity while meah describes 99% pure or fine gold.

[11] 15.5 percent of households noted that they received some form of money from abroad or another province.

**រូបភាព ៥.ការសន្សំរបស់គ្រួសារដែលបានរាយការណ៍ (ខែមករា និងខែមេសា ឆ្នាំ២០២០)**




សំនួរ: ក្នុងខែមករា/មេសា ឆ្នាំ២០២០ តើសមាជិកគ្រួសាររបស់អ្នកមានការសន្សំប្រាក់ (ផ្លាទីន) [មាសសុទ្ធ] ដែរឬទេ?

បន្ថែមពីលើប្រាក់ចំណូលគ្រួសារ

ការសិក្សានេះបានរកឃើញគំរូផ្លាស់ប្តូរជាច្រើនលើបំណុលគ្រួសារ។ នៅចន្លោះខែមករា និងខែមេសា ៣៤ភាគរយនៃប្រាក់កម្ចីមានការផ្លាស់ប្តូរលក្ខខណ្ឌជាពិសេសដោយសារផលប៉ះពាល់នៃជម្ងឺកូវីដ-១៩។ ការផ្លាស់ប្តូរទាំងនេះអាចមើលឃើញនៅក្នុង រូបភាព ៦. ពី ខែមករា ដល់ ខែមេសា មានគ្រួសារមួយចំនួនដែលបានរាយការណ៍ថាពួកគាត់បានយឺតយ៉ាវក្នុងការផ្តល់ប្រាក់សំណង ដែលបានកើនឡើងដល់ ២៣០%។

**រូបភាព ៦. ការផ្លាស់ប្តូរលក្ខខណ្ឌផ្តល់ប្រាក់កម្ចី (ប្រាក់កម្ចីថ្មីៗ)**




សំនួរ: តើលក្ខខណ្ឌនៃការផ្តល់ប្រាក់កម្ចីផ្លាស់ប្តូរយ៉ាងដូចម្តេចដែរ?

បន្ថែមពីលើលក្ខខណ្ឌផ្លាស់ប្តូរ និងលទ្ធភាពនៃការផ្តល់ប្រាក់សំណង មានការរាយការណ៍ថាបានប្រើប្រាស់កម្ចីថ្មីៗត្រឹម ១១ភាគរយ។ ចំពោះកម្ចីថ្មីៗទាំងនេះ ១/៣ ធ្វើកម្ចីដើម្បីធ្វើសំណងទៅកម្ចីផ្សេងៗទៀត ឬដើម្បីផ្គត់ផ្គង់ការចំណាយប្រចាំថ្ងៃ។ រូបភាព ៧. ប្រាប់ពីបញ្ជី ហេតុផលទាំងអស់ ។

**រូបភាព ៧. ហេតុផលនៃការខ្ចី (កម្ចីថ្មី)**




សំនួរ: ហេតុអ្វីបានជាធ្វើកម្ចីថ្មី?

ជាងនេះទៀត គ្រួសារចំនួន ៨៣ បានប្រាប់ថាពួកគាត់បានទទួលជាលក្ខណ:នៃការឧបត្ថម្ភពីរដ្ឋាភិបាលឬអង្គការមិនមែនរដ្ឋាភិបាលពី ខែមករា ដល់ មេសា។ ជាអាទិ លក្ខណ:ដែលទទួលបានមានដូចជា អាហារ សាប៊ូ ឬម៉ាស់ពាក់មុខ។ គ្រួសារចំនួន ១.០០៤ បានប្រាប់ថាមិនបានទទួលការឧបត្ថម្ភទេ។ តម្រូវការគ្រួសារបន្ទាន់បំផុតដែលបានរាយការណ៍នៅក្នុងខែមេសា គឺ លុយ(៥៥,៧ភាគរយ) អាហារ(២៤,៥ភាគរយ) ការពន្យាពេលនៃការសងសំណង(៤,៥ភាគរយ) និង ថ្នាំពេទ្យ/ការថែទាំសុខភាព(៤,៥ភាគរយ)។

ជាមួយនិងទិន្នន័យនៃការស្វែងរកផលប៉ះពាល់នៃមេរោគកូវីដ-១៩លើសហគ្រាសនិងប្រាក់ចំណូលគ្រួសារ ក៏មានការយល់សំខាន់ៗមួយចំនួនទាក់ទងទៅនឹងកត្តាសន្តិសុខស្បៀង និងកសិកម្ម (ធ្វើកសិដ្ឋាន)។ គ្រួសារប្រហែល ១/៥ នៅក្នុងការសិក្សានេះ បានបង្កើតប្រាក់ចំណូលពីរមុខបរកសិកម្មឬរបរនេសាទត្រី ដែលមុខរបរសំខាន់ៗចំនួន៤ រួមមាន ការធ្វើស្រែ ដាំដំឡូងមី ចិញ្ចឹមសត្វ និង ផលិកម្មបន្លែ[12]។ ពីខែមករា ដល់ ខែមេសា មានកំណើន ៩,៧ ភាគរយចំពោះគ្រួសារដែលបានជ្រើសរើសបន្តការលក់ផលិតផលរបស់ខ្លួន និងប្រើប្រាស់ផលដែលប្រមូលបាន ទាំងអស់របស់ពួកគាត់ជំនួសវិញ។ ចំពោះគ្រួសារដែលនៅបន្តលក់ដូរ ត្រូវបានរាយការណ៍ថាមានការធ្លាក់ចុះប្រាក់ចំណូលស្ទើរតែគ្រប់របរកសិកម្ម លើកលែងតែការធ្វើស្រែនិងការចិញ្ចឹមសត្វ[13]។ លទ្ធផលបង្ហាញនៅក្នុងតារាង ៥។

**តារាង ៥. ប្រាក់ចំណូលដែលបានរាយការណ៍ពីការធ្វើមុខរបរកសិកម្ម គិតជាដុល្លា (ខែមករា និង ខែមេសា ឆ្នាំ២០២០)**

| ប្រភេទកសិកម្ម | ការអង្កេត | ប្រាក់ចំណូលមធ្យម ខែមករា | ប្រាក់ចំណូលមធ្យម ខែមេសា | ការផ្លាស់ប្តូរប្រាក់ចំណូល |
|---|---|---|---|---|

[12] At 34.39%, 21.75%, 20.70%, and 13.68% respectively

[13] It is important to note that the decline of farm income may be affected by the seasonality of farm products since April is the off season for most farm activities.

| | | | | |
|---|---|---|---|---|
| បន្លែ | 33 | 300.33 | 204.58 | (95.76) |
| ផ្លែឈើ | 6 | 354.17 | 16.67 | (337.50) |
| ធ្វើស្រែ | 38 | 109.61 | 165.13 | 55.53 |
| នេសាទត្រី | 9 | 123.89 | 67.22 | (56.60) |
| ចិញ្ចឹមសត្វ | 57 | 346.93 | 347.84 | 0.91 |
| កាប់/ដឹកឈើ | 4 | 195.00 | 58.75 | (136.25) |
| ដំឡូងមី | 62 | 356.85 | 122.58 | (234.27) |
| ផ្សេងៗ (បញ្ជាក់) | 5 | 120.00 | 65.20 | (54.80) |
| សរុប | **214** | **283.16** | **194.95** | (88.21) |

ទោះជាយ៉ាងណាក៏ដោយនៅពេលធ្វើការពិនិត្យទិន្នន័យបន្ថែមទៀត ការធ្លាក់ចុះប្រាក់ចំណូលនៃមុខរបរកសិកម្មភាគច្រើនបំផុត អាចជាខេត្តសៀមរាប ដែលមានប្រាក់ចំណូលមធ្យមធ្លាក់ចុះពី ៣៥១,៨៤ដុល្លារអាមេរិក នៅក្នុងខែមករា មក ១៨៦,០១ដុល្លារអាមេរិក នៅក្នុងខែមេសា[14]។ លទ្ធផលជាអវិជ្ជមានេះ គេឃើញមានអត្រាខ្ពស់នៃអ្នកគិតជាកណ្តាលនៅខេត្តសៀមរាបចំពោះបញ្ហាអសន្តិសុខស្បៀងធ្ងន់ធ្ងរ[15]។ សរុបមក ប្រហែល ២០,១% នៃគ្រួសារសំណាក បានប្រាប់ថាជាអ្នកគិតជាកណ្តាលចំពោះបញ្ហាអសន្តិសុខស្បៀងធ្ងន់ធ្ងរ
ដូចដែលបានចាត់ថ្នាក់ទៅតាមពិន្ទុដើមនៃទំហំជួបប្រទះបញ្ហាអសន្តិសុខស្បៀង[16]។

This project is supported through grants from Australia's Department of Foreign Affairs and Trade and The Asia Foundation.

Australian Government
Department of Foreign Affairs and Trade

The Asia Foundation

[14] This is due to the fact that farm households in Siem Reap province are predominantly cultivating cassava for their main source of farm income. The reduced income from cassava also causes the significant decrease of farm income when performing pooled sample comparison.

[15] Followed by Phnom Penh, Svay Rieng, Kampong Speu, and Kampot provinces.

[16] Developed by FAO to measure access to food at the level of individual households. More information on the scale can be found here, http://www.fao.org/3/a-bl354e.pdf